**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសុខាភិបាល

# សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
## ស្តីពី
## ការរកឃើញ ០២ ករណីថ្មីទៀត ជាបុរសទេសចរជនជាតិបារាំង វិជ្ជមានវីរុសកូវីដ១៩ និង ស្ត្រីពិការជនជាតិអង់គ្លេស អវិជ្ជមានវីរុសកូវីដ១៩ ចំនួន០២លើក

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ ឲ្យបានជ្រាបថា លទ្ធផលពីវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា នាវេលាយប់ម៉ោង២១:០០នាទី ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២០ បានបង្ហាញថា សំណាកវត្ថុវិភាគរបស់បុរសចំនួន ០២នាក់ វិជ្ជមានវីរុសកូវីដ១៩ ជាករណីថ្មីបន្ថែមទៀត ដែលមានដូចខាងក្រោមនេះ៖

**១. នៅខេត្តព្រះសីហនុ៖ ០២ ករណី ជាជនជាតិបារាំង**

- បុរសអាយុ ៦៧ឆ្នាំ និង បុរសអាយុ ៨០ឆ្នាំ ស្នាក់នៅសណ្ឋាគារក្នុងក្រុងព្រះសីហនុទាំងអស់គ្នា ជាភ្ញៀវទេសចរណ៍ មកដល់ខេត្តព្រះសីហនុនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ ហើយគ្រោងនៃត្រឡប់ទៅវិញនៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០២០ នេះ។

សម្គាល់៖ បុរសទាំងពីរនាក់ខាងលើនេះ ត្រូវបានដាក់ឲ្យព្យាបាលនៅមន្ទីរពេទ្យខេត្តព្រះសីហនុ។

**២. សុខភាពស្ត្រីជាតិជនអង់គ្លេស** (ពិការ) អាយុ ៦៥ឆ្នាំ មានលទ្ធផលតេស្ត អវិជ្ជមានវីរុសកូវីដ១៩ ចំនួន ០២ដង ហើយត្រូវបានឲ្យចេញពីមន្ទីរពេទ្យរ៉ូយ៉ាល់ភ្នំពេញនៅថ្ងៃស្អែកនេះ។

**៣. សរុបករណីវិជ្ជមានវីរុសកូវីដ១៩ នៅទូទាំងប្រទេស៖**

ត្រឹមម៉ោង២០:០០ ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២០ ករណីវិជ្ជមានវីរុសកូវីដ១៩ សរុបទាំងអស់មានចំនួន ៥៣នាក់ (ស្រី ០៤នាក់ ប្រុស ៤៩នាក់) ដែលក្នុងនោះ មានជនជាតិ ចិន ០១នាក់ (នៅខេត្តព្រះសីហនុ បានជាសះស្បើយ) អង់គ្លេស ០៣នាក់ (ក្នុងនេះ មាន ០១នាក់ អវិជ្ជមានវីរុសកូវីដ១៩ ដែលជាស្ត្រីពិការនៅចំណុច ២ ខាងលើ) កាណាដា ០១នាក់ បែលហ្ស៊ិក ០១នាក់ បារាំង ០៤នាក់ (ក្នុងនេះមានកូនប្រុសបង្កើតអាយុ០៩ខែម្នាក់) ម៉ាឡេស៊ី ១១នាក់ ខ្មែរ ២៩នាក់ (ក្នុងនេះ មានខ្មែរកាន់សាសនាឥស្លាម ២៥នាក់ ដែលក្នុងចំណោម២៥នាក់នេះ មានស្ត្រី០២នាក់ជាភរិយាឆ្លងពីស្វាមី និងបុរសម្នាក់ឆ្លងដោយការប៉ះពាល់ជិតស្និទ្ធជាមួយបុគ្គលវិជ្ជមានវីរុសកូវីដ)។



ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

ក្រុមការងាររបស់ក្រសួងសុខាភិបាល កំពុងតែធ្វើកិច្ចការស្រាវជ្រាវករណីថ្មីជាបន្តទៀត ហើយនឹងបន្តជម្រាបជូនដល់បងប្អូនសាធារណជន ប្រសិនបើមានរកឃើញករណីវិជ្ជមានវីរុសកូវីដ១៩ ថ្មីណាផ្សេងទៀត។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិក និងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវឌ្ឍនៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃសៅរ៍ ១៣រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២០

វេជ្ជបណ្ឌិត **ឱ វណ្ណឌីន**

រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យ

ក្រសួងសុខាភិបាល នៃព្រះរាជាណាចក្រកម្ពុជា